# សន្ធិសញ្ញាស្តីពីច្បាប់ប្រកាសនីយបត្រតក្កកម្ម
## មាតិកា


| | |
|---|---|
| មាត្រា១ | ពាក្យបំព្រួញ |
| មាត្រា២ | គោលការណ៍ទូទៅ |
| មាត្រា៣ | សំណុំលិខិតស្នើសុំ និងប្រកាសនីយបត្រតក្កកម្មដែលសន្ធិសញ្ញានេះអនុវត្ត |
| មាត្រា៤ | ការលើកលែងដែលទាក់ទងនឹងបញ្ហាសន្តិសុខ |
| មាត្រា៥ | កាលបរិច្ឆេទនៃការសុំចុះបញ្ជី |
| មាត្រា៦ | សំណុំលិខិតស្នើសុំ |
| មាត្រា៧ | ការតំណាង |
| មាត្រា៨ | ព័ត៌មាន អាសយដ្ឋាន |
| មាត្រា៩ | សេចក្តីជូនដំណឹង |
| មាត្រា១០ | សុពលភាពនៃប្រកាសនីយបត្រតក្កកម្ម ការលុបចោល |
| មាត្រា១១ | ការលើកលែងចំពោះរយៈពេល |
| មាត្រា១២ | ការផ្តល់សិទ្ធិឡើងវិញបន្ទាប់ពីឃើញមានការយកចិត្តទុកដាក់ត្រឹមត្រូវ ឬ អចេតនាដោយការិយាល័យ |
| មាត្រា១៣ | ការកែតម្រូវ ឬ ការបន្ថែមសេចក្តីអះអាងអាទិភាព ការផ្តល់សិទ្ធិអាទិភាពឡើងវិញ |
| មាត្រា១៤ | បទបញ្ជា |
| មាត្រា១៥ | ទំនាក់ទំនងជាមួយអនុសញ្ញាទីក្រុងប៉ារីស |
| មាត្រា១៦ | អានុភាពនៃការកែប្រែ វិសោធនកម្ម និងការផ្លាស់ប្តូរនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម |
| មាត្រា១៧ | សន្និបាត |
| មាត្រា១៨ | ការិយាល័យអន្តរជាតិ |
| មាត្រា១៩ | ការកែប្រែ |
| មាត្រា២០ | ការក្លាយជាភាគីនៃសន្ធិសញ្ញា |
| មាត្រា២១ | ការចូលជាធរមាន កាលបរិច្ឆេទអានុភាពនៃការផ្តល់សច្ចាប័ននិងការចូលជាសមាជិក |
| មាត្រា២២ | ការអនុវត្តន៍សន្ធិសញ្ញាចំពោះសំណុំលិខិតស្នើសុំនិងប្រកាសនីយបត្រតក្កកម្មដែលមាន |
| មាត្រា២៣ | ខដាក់លក្ខខណ្ឌ |
| មាត្រា២៤ | ការប្រកាសដកខ្លួនចេញពីសន្ធិសញ្ញា |
| មាត្រា២៥ | ភាសានៃសន្ធិសញ្ញា |
| មាត្រា២៦ | ការចុះហត្ថលេខាលើសន្ធិសញ្ញា |

## មាត្រា១

## ពាក្យបំព្រួញ

ជាគោលបំណងនៃសន្ធិសញ្ញានេះ លើកលែងតែបញ្ជាក់យ៉ាងច្បាស់ផ្សេងពីនេះ:

(i) "ការិយាល័យ" មានន័យថា អាជ្ញាធរនៃភាគីហត្ថលេខីដែលទទួលខុសត្រូវផ្តល់ប្រកាសនីយបត្រតក្កកម្ម ឬទទួលខុសត្រូវចំពោះបញ្ញាកម្មផ្សេងទៀតដែលគ្រប់គ្រងដោយសន្ធិសញ្ញានេះ

(ii) "សំណុំលិខិតស្នើសុំ" មានន័យថា សំណុំលិខិតស្នើសុំដើម្បីផ្តល់ប្រកាសនីយបត្រតក្កកម្ម ដូចមានចែងក្នុងមាត្រា៣

(iii) "ប្រកាសនីយបត្រតក្កកម្ម" មានន័យថា ប្រកាសនីយបត្រតក្កកម្ម ដូចមានចែងក្នុងមាត្រា៣

(iv) ចំពោះ "បុគ្គល" ត្រូវបកស្រាយជាពិសេសដោយរួមបញ្ចូលទាំងរូបវន្តបុគ្គលនិងនីតិបុគ្គល

(v) "ទំនាក់ទំនង" មានន័យថា សំណុំលិខិតស្នើសុំណាមួយ ឬ ពាក្យសុំ សេចក្តីប្រកាស ឯកសារ ការឆ្លើយតបឬព័ត៌មានផ្សេងទៀតណាមួយដែលទាក់ទងនឹងសំណុំលិខិតស្នើសុំឬប្រកាសនីយបត្រតក្កកម្ម ទោះបីទាក់ទងឬមិនទាក់ទងនឹងនីតិវិធីក្នុងសន្ធិសញ្ញានេះ ដែលបានដាក់នៅការិយាល័យ

(vi) "កំណត់ត្រាការិយាល័យ" មានន័យថា ការបណ្តុំព័ត៌មានដែលរក្សាទុកដោយការិយាល័យ ទាក់ទងនឹង និងរួមទាំងសំណុំលិខិតស្នើសុំដែលបានដាក់ និងប្រកាសនីយបត្រតក្កកម្ម ដែលផ្តល់ឱ្យដោយការិយាល័យ ឬអាជ្ញាធរផ្សេងទៀតដែល មានអានុភាពចំពោះភាគីហត្ថលេខីពាក់ព័ន្ធ ដោយមិនគិតពីមធ្យោបាយរក្សាទុកព័ត៌មានទាំងនេះ

(vii) "ការកត់ត្រា" មានន័យថា សកម្មភាពណាមួយនៃការបញ្ចូលព័ត៌មានក្នុងកំណត់ត្រាការិយាល័យ

(viii) "អ្នកដាក់ពាក្យសុំ" មានន័យថា បុគ្គលដែលកំណត់ត្រាការិយាល័យបង្ហាញ អនុលោមតាមច្បាប់ដែលអនុវត្ត ថាជា បុគ្គលដែលកំពុងស្នើសុំប្រកាសនីយបត្រតក្កកម្ម ឬ ជាបុគ្គលផ្សេងទៀតដែលកំពុងដាក់ពាក្យ ឬកំពុងតាមដានសំណុំលិខិតស្នើសុំ

(ix) "ម្ចាស់សិទ្ធិ" មានន័យថា បុគ្គលដែលកំណត់ត្រាការិយាល័យបង្ហាញថាជាម្ចាស់ប្រកាស នីយបត្រតក្កកម្ម

(x) "អ្នកតំណាង" មានន័យថា អ្នកតំណាងតាមច្បាប់ដែលអនុវត្ត

(xi) "ហត្ថលេខា" មានន័យថា មធ្យោបាយនៃការបង្ហាញអត្តសញ្ញាណខ្លួនឯង

(xii) "ភាសាដែលទទួលស្គាល់ដោយការិយាល័យ" មានន័យថា ភាសាណាមួយដែលទទួលស្គាល់ដោយការិយាល័យតាមនីតិវិធីពាក់ព័ន្ធចំពោះការិយាល័យ

(xiii) "ការបកប្រែ" មានន័យថា ការបកប្រែទៅជាភាសាមួយ ឬ ក្នុងករណីសមស្រប ជាការបកប្រែតាមសំលេងទៅជាបណ្តុំនៃអក្ខរក្រមឬបណ្តុំនៃតួរអក្សរ ដែលទទួលស្គាល់ដោយការិយាល័យ

(xiv) "នីតិវិធីចំពោះការិយាល័យ" មានន័យថា នីតិវិធីណាមួយកំពុងដំណើរការចំពោះការិយា ល័យ ទាក់ទងនឹងសំណុំលិខិតស្នើសុំឬប្រកាសនីយបត្រតក្កកម្ម

(xv) ការលើកលែងនៅពេលដែលបរិបទបញ្ជាក់ផ្សេង ពាក្យក្នុងទម្រង់ឯកវចនៈអាចជាពហុវចនៈ និងពាក្យក្នុងទម្រង់ពហុវចនៈអាចជាឯកវចនៈ ហើយសព្វនាមបុគ្គលភេទប្រុសអាចបញ្ចូលភេទស្រីផងដែរ

(xvi) "អនុសញ្ញាទីក្រុងប៉ារីស" មានន័យថា អនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី២០ ខែមីនា ឆ្នាំ ១៨៨៣ ដែលបានធ្វើការកែប្រែនិងវិសោធនកម្ម

(xvii) "សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម" មានន័យថា សន្ធិសញ្ញាសហប្រតិ បត្តិការប្រកាសនីយបត្រតក្កកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧០ រួមទាំងបទបញ្ជានិងការណែនាំរដ្ឋបាលក្នុងសន្ធិសញ្ញានេះ ដែលបានកែប្រែ វិសោធនកម្ម និងផ្លាស់ប្តូរ

(xviii) "ភាគីហត្ថលេខី" មានន័យថា រដ្ឋ ឬ អង្គការអន្តររដ្ឋាភិបាលណាមួយដែលជាភាគីនៃសន្ធិសញ្ញានេះ

(xix) "ច្បាប់ដែលអនុវត្ត" មានន័យថា នៅពេលដែលភាគីហត្ថលេខីជារដ្ឋ គឺច្បាប់នៃរដ្ឋនោះ ហើយនៅពេលដែលភាគីហត្ថលេខីជាអង្គការអន្តររដ្ឋាភិបាល គឺជាលិខិតបទដ្ឋានគតិយុត្តដែលរៀបចំការប្រព្រឹត្តទៅរបស់អង្គការអន្តររដ្ឋាភិបាលនោះ

(xx) "លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន" ត្រូវបកស្រាយដោយរួមបញ្ចូលលិខិតុបករណ៍ទាំងឡាយនៃការទទួលយក ឬការអនុម័តយល់ព្រម

(xxi) "អង្គការ" មានន័យថា អង្គការកម្មសិទ្ធិបញ្ញាពិភពលោក

(xxii) "ការិយាល័យអន្តរជាតិ" មានន័យថា ការិយាល័យអន្តរជាតិនៃអង្គការ

(xxiii) "អគ្គនាយក" មានន័យថា អគ្គនាយកនៃអង្គការ។

## មាត្រា២

## គោលការណ៍ទូទៅ

(១) [ លក្ខខណ្ឌផ្តល់ភាពអនុគ្រោះ]

តាមទស្សនៈនៃអ្នកដាក់ពាក្យសុំនិងម្ចាស់សិទ្ធិ ភាគីហត្ថលេខីមានសិទ្ធិចែងពីលក្ខខណ្ឌដែលមានលក្ខណៈអនុគ្រោះជាងលក្ខខណ្ឌដែលមានចែងក្នុងសន្ធិសញ្ញានេះនិងបទបញ្ជានៃ លើកលែងតែមាត្រា៥។

(២) [ គ្មានបទបញ្ជានៃច្បាប់ប្រកាសនីយបត្រតក្កកម្មជាសារធាតុ]

គ្មានបទប្បញ្ញត្តិណាមួយនៃសន្ធិសញ្ញានេះឬបទបញ្ជា ត្រូវបានបកស្រាយដើម្បីកម្រិតសេរីភាពភាគីហត្ថលេខី ក្នុងការចែងលក្ខខណ្ឌស្តីពីច្បាប់សារធាតុនៃប្រកាសនីយបត្រតក្កកម្ម ដែលភាគីនេះចង់បានឡើយ។

## មាត្រា៣

## សំណុំលិខិតស្នើសុំ និងប្រកាសនីយបត្រតក្កកម្មដែលសន្ធិសញ្ញានេះអនុវត្ត

(១) [ សំណុំលិខិតស្នើសុំ ]

(ក) បទប្បញ្ញត្តិនៃសន្ធិសញ្ញានេះនិងបទបញ្ជា ត្រូវអនុវត្តចំពោះសំណុំលិខិតស្នើសុំជាតិនិងតំបន់ចំពោះប្រកាសនីយបត្រតក្កម្មសម្រាប់តក្កកម្ម និងប្រកាសនីយបត្រតក្កកម្មសម្រាប់ការបន្ថែមដែលបានដាក់នៅឬសម្រាប់ការិយាល័យនៃភាគីហត្ថលេខី ហើយដែលជាៈ

(i) ប្រភេទសំណុំលិខិតស្នើសុំដែលអនុញ្ញាតដើម្បីដាក់ជាសំណុំលិខិតស្នើសុំអន្តរជាតិក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

(ii) សំណុំលិខិតស្នើសុំបំបែកនៃប្រភេទសំណុំលិខិតស្នើសុំ ដូចមានចែងក្នុងចំនុចទី(i) ចំពោះប្រកាសនីយបត្រតក្កកម្មសម្រាប់តក្កកម្ម ឬប្រកាសនីយបត្រតក្កកម្មសម្រាប់ការបន្ថែម ដូចមានចែង ក្នុងមាត្រា៤(ឆ)(១) ឬ (២) នៃអនុសញ្ញាទីក្រុងប៉ារីស។

(ខ) លើកលែងតែបទប្បញ្ញត្តិនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ និង បទបញ្ជាត្រូវអនុវត្តចំពោះសំណុំលិខិតស្នើសុំអន្តរជាតិចំពោះប្រកាសនីយបត្រតក្កកម្មសម្រាប់តក្កកម្ម និងប្រកាសនីយបត្រតក្កកម្មសម្រាប់ការបន្ថែម ក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មៈ

(i) ចំពោះរយៈពេលដែលអាចអនុវត្តបានក្នុងមាត្រា២២ និងមាត្រា៣៩(១) នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មក្នុងការិយាល័យភាគីហត្ថលេខី

(ii) ចំពោះនីតិវិធីណាមួយដែលបានចាប់ផ្តើមត្រឹម ឬចាប់ផ្តើមបន្ទាប់ពីកាលបរិច្ឆេទនៃដំណើរការ ឬការត្រួតពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ អាចចាប់ផ្តើមតាមមាត្រា២៣ ឬមាត្រា៤០នៃសន្ធិសញ្ញានោះ។

(២) [ ប្រកាសនីយបត្រតក្កកម្ម ]

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះនិងបទបញ្ជា ត្រូវអនុវត្តចំពោះប្រកាសនីយបត្រតក្កកម្មសម្រាប់តក្កកម្មកម្រិតជាតិនិងតំបន់ និង ប្រកាសនីយបត្រតក្កកម្មសម្រាប់ការបន្ថែមកម្រិតជាតិ និង

តំបន់ ដែលបានផ្តល់ឱ្យដោយមានអានុភាពចំពោះភាគីហត្ថលេខី។

## មាត្រា៤
## ការលើកលែងដែលទាក់ទងនឹងបញ្ហាសន្តិសុខ

សន្ធិសញ្ញានេះនិងបទបញ្ជា មិនត្រូវកម្រិតសេរីភាពភាគីហត្ថលេខី ក្នុងការចាត់វិធានការដែលចាំបាច់ដើម្បីការពារផលប្រយោជន៍សន្តិសុខជាសារវន្ត។

## មាត្រា៥
## កាលបរិច្ឆេទនៃការសុំចុះបញ្ជី

(១) [ ធាតុនៃសំណុំលិខិតស្នើសុំ ]

(ក) លើកលែងតែមានការចែងផ្សេងក្នុងបទបញ្ជា និងលើកលែងកថាខណ្ឌទី(២)ដល់ទី(៨) ភាគីហត្ថលេខី ត្រូវចែងថា កាលបរិច្ឆេទនៃការសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំត្រូវជាកាលបរិច្ឆេទដែលការិយាល័យទទួលបានធាតុទាំងអស់ដូចខាងក្រោម ដែលបានដាក់ ជាជម្រើសរបស់អ្នកដាក់ពាក្យសុំ ក្នុងទម្រង់ក្រដាស់ ឬ មធ្យោបាយផ្សេងដែលអនុញ្ញាតដោយការិយាល័យ សម្រាប់គោលបំណងនៃកាលបរិច្ឆេទនៃការសុំចុះបញ្ជីៈ

(i) ការបញ្ជាក់យ៉ាងច្បាស់លាស់ឬគ្រប់គ្រាន់ ដែលមានអានុភាពបញ្ជាក់ថា ធាតុទាំង ឡាយត្រូវមានក្នុងសំណុំលិខិតស្នើសុំ

(ii) ការបញ្ជាក់អំពីអត្តសញ្ញាណនៃអ្នកដាក់ពាក្យសុំ ឬ ការបញ្ជាក់ដែលអនុញ្ញាតឱ្យការិយាល័យអាចទាក់ទងជាមួយអ្នកដាក់ពាក្យសុំបាន

(iii) ផ្នែកមួយនៃសំណុំលិខិតស្នើសុំដែលនៅលើផ្នែកនោះមានបញ្ជាក់នូវសេចក្តីអធិប្បាយ។

(ខ) ជាគោលបំណងនៃកាលបរិច្ឆេទការសុំចុះបញ្ជី ភាគីហត្ថលេខីអាចទទួលយកគំនូសបង្ហាញជាធាតុដូចមានចែងក្នុងអនុកថាខណ្ឌ(ក)(iii)។

(គ) ជាគោលបំណងនៃកាលបរិច្ឆេទការសុំចុះបញ្ជី ភាគីហត្ថលេខីអាចតម្រូវឱ្យផ្តល់ទាំងព័ត៌មានអំពីអត្តសញ្ញាណនៃអ្នកដាក់ពាក្យសុំនិងព័ត៌មាន ដែលអាចអនុញ្ញាតឱ្យការិយាល័យអាចទាក់ទងជាមួយអ្នកដាក់ពាក្យស្នើសុំបាន ឬភាគីហត្ថលេខីអាចទទួលយកភស្តុតាងអំពីអត្តសញ្ញាណនៃអ្នកដាក់ពាក្យសុំ ឬដែលអនុញ្ញាតឱ្យការិយាល័យអាចទាក់ទងជាមួយអ្នកដាក់ពាក្យសុំបាន ជាធាតុដូចមានចែងក្នុងអនុកថាខណ្ឌ(ក)(ii)។

(២) [ ភាសា]

(ក) ភាគីហត្ថលេខីអាចតម្រូវឱ្យការបញ្ជាក់ដែលមានចែងក្នុងកថាខណ្ឌទី(១)(ក)(i) និង(ii)ធ្វើជាភាសាមួយដែលទទួលយកដោយការិយាល័យ។

(ខ) ផ្នែកដែលមានចែងក្នុងកថាខណ្ឌទី(១)(ក)(iii) អាចដាក់ ជាភាសាណាមួយ ជាគោលបំណងនៃកាលបរិច្ឆេទការសុំចុះបញ្ជី។

(៣) [ការជូនដំណឹង]

នៅពេលដែលសំណុំលិខិតស្នើសុំមិនអនុលោមតាមលក្ខខណ្ឌតម្រូវមួយឬច្រើន ដែលត្រូវអនុវត្តដោយការិយាល័យក្នុងកថាខណ្ឌទី(១)និងទី(២) ការិយាល័យត្រូវដំណឹងដល់អ្នកដាក់ពាក្យសុំភ្លាមតាមតែអាចធ្វើទៅបាន ដោយផ្តល់ឱកាសឱ្យបំពេញលក្ខខណ្ឌតម្រូវណាមួយនេះ និងដើម្បីធ្វើការសង្កេត តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា។

(៤) [ការបំពេញលក្ខខណ្ឌតម្រូវពេលក្រោយ ]

(ក) នៅពេលដែលលក្ខខណ្ឌតម្រូវមួយឬច្រើន ដែលត្រូវអនុវត្តដោយភាគីហត្ថលេខីក្នុងកថាខណ្ឌទី(១)និងទី(២)មិនបានបំពេញ ក្នុងសំណុំលិខិតស្នើសុំដែលបានដាក់ពីដំបូង កាលបរិច្ឆេទនៃការសុំចុះបញ្ជីត្រូវជាកាលបរិច្ឆេទនៅពេលដែលរាល់លក្ខខណ្ឌតម្រូវទាំងអស់ដែលត្រូវអនុវត្តដោយភាគីហត្ថលេខីតាមកថាខណ្ឌទី(១)និងទី(២) ត្រូវបានបំពេញនាពេលក្រោយ លើកលែងតែអនុកថាខណ្ឌ(ខ)និងកថាខណ្ឌទី(៦)។

(ខ) នៅពេលដែលលក្ខខណ្ឌតម្រូវមួយឬច្រើនដូចមានចែងក្នុងអនុកថាខណ្ឌ(ក) មិនត្រូវបានបំពេញតាមរយៈពេលដែលកំណត់ក្នុងបទបញ្ជា ភាគីហត្ថលេខីអាចចែងថាសំណុំលិខិតស្នើសុំនោះត្រូវចាត់ទុកថាមិនបានដាក់។ នៅពេលដែលសំណុំលិខិតស្នើសុំ ត្រូវចាត់ទុកថាមិនបានដាក់ ការិយាល័យត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំ ដោយបញ្ជាក់ពីមូលហេតុ។

(៥) [ការជូនដំណឹងពាក់ព័ន្ធនឹងការខ្វះផ្នែកណាមួយនៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញ ]

ពេលចុះកាលបរិច្ឆេទនៃការសុំចុះបញ្ជី នៅពេលដែលការិយាល័យរកឃើញថាផ្នែកមួយនៃសេចក្តីអធិប្បាយបានខ្វះក្នុងសំណុំលិខិតស្នើសុំ ឬសំណុំលិខិតស្នើសុំនោះយោងទៅគំនូសបង្ហាញដែលបានខ្វះក្នុងសំណុំលិខិតស្នើសុំ ការិយាល័យត្រូវជូនដំណឹងភ្លាមដល់អ្នកដាក់ពាក្យសុំ។

(៦) [ កាលបរិច្ឆេទនៃការសុំចុះបញ្ជី នៅពេលដែលបានដាក់ផ្នែកនៃសេចក្តីអធិប្បាយឬគំនូសបង្ហាញដែលខ្វះ]

(ក) នៅពេលដែលផ្នែកដែលខ្វះនៃសេចក្តីអធិប្បាយឬគំនូសបង្ហាញបានដាក់នៅការិយាល័យតាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា ផ្នែកនេះនៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញត្រូវបញ្ចូលក្នុងសំណុំលិខិតស្នើសុំ ហើយ លើកលែងតែអនុកថាខណ្ឌ(ខ)និង(គ) កាលបរិច្ឆេទនៃការសុំចុះបញ្ជីត្រូវជាកាលបរិច្ឆេទដែលការិយាល័យទទួលបានផ្នែកនេះនៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញ ឬត្រូវជាកាលបរិច្ឆេទនៃការបំពេញរាល់លក្ខខណ្ឌតម្រូវទាំងអស់ ដែលត្រូវអនុវត្តដោយភាគីហត្ថលេខីតាមកថាខណ្ឌទី(១)និងទី(២) ដោយយកកាលបរិច្ឆេទណាដែលយូរជាងគេ។

(ខ) នៅពេលដែលផ្នែកដែលខ្វះនៃសេចក្តីអធិប្បាយឬគំនូសបង្ហាញ បានដាក់តាមអនុកថាខណ្ឌ(ក)ដើម្បីកែតម្រូវការលុបចោលពីសំណុំលិខិតស្នើសុំ តាមកាលបរិច្ឆេទដែលធាតុមួយឬច្រើនដូចមានចែងក្នុងកថាខណ្ឌទី(១)(ក)ត្រូវបានទទួលពីដំបូងដោយការិយាល័យ ដែលអះអាងអាទិភាពនៃសំណុំលិខិតស្នើសុំមុន តាមសំណើរបស់អ្នកដាក់ពាក្យសុំដែលបានដាក់តាមរយៈពេលដែល

បានកំណត់ក្នុងបទបញ្ជានិងលើកលែងតែលក្ខខណ្ឌតម្រូវដែលបានកំណត់ក្នុងបទបញ្ជា កាលបរិច្ឆេទនៃការសុំចុះបញ្ជីត្រូវជាកាលបរិច្ឆេទនៃការបំពេញរាល់លក្ខខណ្ឌតម្រូវទាំងអស់ ដែលត្រូវអនុវត្តដោយភាគីហត្ថលេខីតាមកថាខណ្ឌទី(១)និងទី(២)។

(គ) នៅពេលដែលផ្នែកដែលខ្វះនៃសេចក្តីអធិប្បាយ ឬគំនូសបង្ហាញបានដាក់តាមអនុកថាខណ្ឌ(ក)ត្រូវបានដកយកទៅវិញតាមរយៈពេលដែលបានកំណត់ដោយភាគីហត្ថលេខី កាលបរិច្ឆេទនៃការសុំចុះបញ្ជីត្រូវជាកាលបរិច្ឆេទនៃការបំពេញលក្ខខណ្ឌតម្រូវ ដែលត្រូវអនុវត្តដោយភាគីហត្ថលេខីតាមកថាខណ្ឌទី(១)និងទី(២) ។

(៧) [ការជំនួសសេចក្តីអធិប្បាយនិងគំនូសបង្ហាញដោយយោងទៅសំណុំលិខិតស្នើសុំដែលបានដាក់ពីមុន]

(ក) លើកលែងតែលក្ខខណ្ឌតម្រូវដែលបានកំណត់ក្នុងបទបញ្ជា ការយោងទៅលើសំណុំលិខិតស្នើសុំដែលបានដាក់ពីមុន ដែលធ្វើឡើងបន្ទាប់ពីការដាក់សំណុំលិខិតស្នើសុំ ជាភាសាមួយដែលទទួលយកដោយការិយាល័យ ត្រូវជំនួសសេចក្តីអធិប្បាយនិងគំនូសបង្ហាញណាមួយ ជាគោលបំណងនៃកាលបរិច្ឆេទការសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ។

(ខ) នៅពេលដែលលក្ខខណ្ឌតម្រូវដូចមានចែងក្នុងអនុកថាខណ្ឌ(ក) មិនបានបំពេញសំណុំលិខិតស្នើសុំត្រូវចាត់ទុកថាមិនបានដាក់។ នៅពេលដែលសំណុំលិខិតស្នើសុំត្រូវចាត់ទុកថាមិនបានដាក់ ការិយាល័យត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំ ដោយបញ្ជាក់ពីមូលហេតុ។

(៨) [ ការលើកលែង]

មាត្រានេះ មិនត្រូវកម្រិតៈ

(i) តាមមាត្រា៤(ឆ)(១)ឬ(២)នៃអនុសញ្ញាទីក្រុងប៉ារីស សិទ្ធិអ្នកដាក់ពាក្យសុំ ដើម្បីរក្សាជា កាលបរិច្ឆេទសំណុំលិខិតស្នើសុំបំបែកដូចមានចែងក្នុងមាត្រានោះនូវកាលបរិច្ឆេទសំណុំលិខិតស្នើសុំដើមដូចមានចែងក្នុងមាត្រានោះ និងរក្សាអត្ថប្រយោជន៍នៃសិទ្ធិអាទិភាព ប្រសិនបើមាន។

(ii) សេរីភាពភាគីហត្ថលេខីក្នុងការអនុវត្តន៍លក្ខខណ្ឌតម្រូវណាមួយដែលចាំបាច់សម្រាប់ផ្តល់អត្ថប្រយោជន៍នៃកាលបរិច្ឆេទការសុំចុះបញ្ជីសំណុំលិខិតស្នើសុំមុន ឱ្យទៅសំណុំលិខិតស្នើសុំប្រភេទណាមួយដូចកំណត់ក្នុងបទបញ្ជា។

## មាត្រា៦

## សំណុំលិខិតស្នើសុំ

(១) [ ទម្រង់ ឬមាតិកានៃសំណុំលិខិតស្នើសុំ ]

លើកលែងតែមានចែងផ្សេងដោយសន្ធិសញ្ញានេះ គ្មានភាគីហត្ថលេខីណាត្រូវតម្រូវឱ្យបំពេញលក្ខខណ្ឌតម្រូវណាមួយពាក់ព័ន្ធនឹងទម្រង់ ឬមាតិកានៃសំណុំលិខិតស្នើសុំផ្សេងពី ឬបន្ថែមទៅលើៈ

(i) លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងទម្រង់ឬមាតិកាដែលមានចែងចំពោះសំណុំលិខិតស្នើសុំ

អន្តរជាតិក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

(ii) លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងទម្រង់ឬមាតិកា ដែល តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម អាចទាមទារដោយការិយាល័យនៃ ឬការិយាល័យតំណាងរដ្ឋជាភាគីណាមួយនៃសន្ធិសញ្ញានេះ នៅពេលចាប់ផ្តើមដំណើរការ ឬចាប់ផ្តើមត្រួតពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ ដូចមានចែងក្នុងមាត្រា២៣ ឬ មាត្រា៤០នៃសន្ធិសញ្ញានេះ

(iii) លក្ខខណ្ឌតម្រូវផ្សេងៗដែលបានកំណត់ក្នុងបទបញ្ជា។

(២) [ ទម្រង់ពាក្យសុំ ]

(ក) ភាគីហត្ថលេខីមួយអាចតម្រូវឱ្យ មាតិកានៃសំណុំលិខិតស្នើសុំ ដែលដូចនឹងមាតិកានៃពាក្យសុំនៃសំណុំលិខិតស្នើសុំអន្តរជាតិ តាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម បង្ហាញក្នុងទម្រង់ពាក្យសុំដែលកំណត់ដោយភាគីហត្ថលេខីនោះ។ ភាគីហត្ថលេខីក៏អាចតម្រូវឱ្យមានក្នុងទម្រង់ពាក្យសុំនោះនូវមាតិកាផ្សេងទៀតដែលអនុញ្ញាតតាមកថាខណ្ឌទី(១)(ii) ឬដែលបានកំណត់ក្នុងបទបញ្ជាដែលស្របនឹងកថាខណ្ឌទី(១)(iii) ។

(ខ) ថ្វីបើមានចែងក្នុងកថាខណ្ឌ(ក) និងលើកលែងតែមាត្រា៨(១) ភាគីហត្ថលេខីត្រូវទទួលយកការបង្ហាញនៃមាតិកា ដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ក្នុងទម្រង់ពាក្យសុំដែលមានចែងក្នុងបទបញ្ជា។

(៣) [ ការបកប្រែ ]

ភាគីហត្ថលេខីអាចតម្រូវឱ្យមានការបកប្រែផ្នែកណាមួយនៃសំណុំលិខិតស្នើសុំ ដែលមិនមែនជាភាសាដែលទទួលយកដោយការិយាល័យ។ ភាគីហត្ថលេខីក៏អាចតម្រូវផងដែរឱ្យបកប្រែផ្នែកនៃសំណុំលិខិតស្នើសុំ ពីភាសាដែលទទួលយកដោយការិយាល័យទៅជាភាសាផ្សេងទៀតដែលទទួលយកដោយការិយាល័យ ដូចមានកំណត់ក្នុងបទបញ្ជា។

(៤) [ កម្រៃ ]

ភាគីហត្ថលេខីអាចតម្រូវឱ្យបង់កម្រៃចំពោះសំណុំលិខិតស្នើសុំ។ ភាគីហត្ថលេខីអាចអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ទាក់ទងនឹងការបង់កម្រៃសំណុំលិខិតស្នើសុំ។

(៥) [ឯកសារអាទិភាព]

នៅពេលដែលមានការអះអាងអះអាទិភាពនៃសំណុំលិខិតស្នើសុំពីមុន ភាគីហត្ថលេខីអាចតម្រូវឱ្យដាក់ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំស្នើសុំពីមុននិងការបកប្រែ ក្នុងករណីសំណុំលិខិតស្នើសុំពីមុនមិនធ្វើឡើងក្នុងភាសាដែលទទួលយកដោយការិយាល័យ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវដែលកំណត់ក្នុងបទបញ្ជា។

(៦) [ភស្តុតាង]

ភាគីហត្ថលេខីអាចតម្រូវឱ្យភស្តុតាងដែលពាក់ព័ន្ធនឹងបញ្ហាណាមួយដូចមានចែងក្នុងកថាខណ្ឌទី(១) ឬទី(២) ឬ ក្នុងសេចក្តីប្រកាសអាទិភាព ឬ ការបកប្រែណាមួយដូចមានចែងក្នុងកថាខណ្ឌទី(៣) ឬទី(៥) ដាក់នៅការិយាល័យនៃភាគីហត្ថលេខី ក្នុងពេលដំណើរការសំណុំលិខិតស្នើសុំ តែក្នុងករណីដែលការិយាល័យ អាចសង្ស័យដោយសមហេតុសមផលពីភាពពិតប្រាកដនៃបញ្ហានោះ ឬពីភាពត្រឹមត្រូវនៃការបកប្រែនោះ។

(៧) [ ការជូនដំណឹង ]

នៅពេលដែលមិនបានបំពេញលក្ខខណ្ឌតម្រូវមួយឬច្រើនដែលត្រូវអនុវត្តដោយភាគីហត្ថលេខីតាមកថាខណ្ឌទី(១)ដល់ទី(៦) ការិយាល័យត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំ ដោយផ្តល់ឱកាសឱ្យមកបំពេញលក្ខខណ្ឌតម្រូវ និងដើម្បីធ្វើការសង្កេត តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា។

(៨) [ ការមិនបំពេញលក្ខខណ្ឌតម្រូវ ]

(ក) នៅពេលដែលមិនបានបំពេញលក្ខខណ្ឌតម្រូវមួយឬច្រើនដែលត្រូវអនុវត្តដោយភាគីហត្ថលេខីតាមកថាខណ្ឌទី(១)ដល់ទី(៦) តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា ភាគីហត្ថលេខីអាចអនុវត្តទណ្ឌកម្មដូចមានចែងក្នុងច្បាប់របស់ខ្លួន លើកលែងតែអនុកថាខណ្ឌ(ខ)និងមាត្រា៥ និងមាត្រា១០ ។

(ខ) នៅពេលដែលមិនបានបំពេញលក្ខខណ្ឌតម្រូវណាមួយដែលត្រូវអនុវត្តដោយភាគីហត្ថលេខីតាមកថាខណ្ឌទី(១) ទី(៥) ឬទី(៦)ចំពោះការអះអាងអាទិភាព តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា ការអះអាងអាទិភាពអាចចាត់ទុកថាមិនបានធ្វើឡើយ។ លើកលែងតែមាត្រា៥(៧)(ខ) មិនត្រូវអនុវត្តទណ្ឌកម្មផ្សេងទៀតឡើយ។

## មាត្រា៧
## ការតំណាង

(១) [ អ្នកតំណាង ]

(ក) ភាគីហត្ថលេខីអាចតម្រូវថា អ្នកតំណាងដែលត្រូវបានជ្រើសតាំងសម្រាប់គោលបំណងនៃនីតិវិធីចំពោះមុខការិយាល័យណាមួយៈ

(i) តាមច្បាប់ដែលអនុវត្ត មានសិទ្ធិអនុវត្តចំពោះមុខការិយាល័យ លើសំណុំលិខិតស្នើសុំនិងប្រកាសនីយបត្រតក្កកម្ម

(ii) ផ្តល់ជូនជា អាសយដ្ឋានរបស់ខ្លួន នូវអាសយដ្ឋានលើដែនដីដែលកំណត់ដោយភាគីហត្ថលេខី។

(ខ)លើកលែងតែអនុកថាខណ្ឌ(គ) ទាក់ទងនឹងនីតិវិធីចំពោះមុខការិយាល័យ សកម្មភាពមួយដែលធ្វើឡើងដោយអ្នកតំណាងឬទាក់ទងនឹងអ្នកតំណាងដែលបានបំពេញលក្ខខណ្ឌតម្រូវដែលអនុវត្តដោយភាគីហត្ថលេខីក្នុងអនុកថាខណ្ឌ(ក) ត្រូវមានអានុភាពជាសកម្មភាពដែលធ្វើឡើងដោយ ឬ

ទាក់ទងនឹងអ្នកដាក់ពាក្យសុំ ម្ចាស់ ឬ បុគ្គលមានប្រយោជន៍ផ្សេងទៀត ដែលជ្រើសតាំងអ្នកតំណាងនោះ។

(គ) ភាគីហត្ថលេខីអាចចែងថា ក្នុងករណីនៃសម្បថ ឬសេចក្ដីអះអាង ឬការលុបចោលលិខិតផ្ទេរសិទ្ធិ ហត្ថលេខារបស់អ្នកតំណាងមិនត្រូវមានអានុភាពជាហត្ថលេខារបស់អ្នកដាក់ពាក្យសុំ ម្ចាស់ ឬបុគ្គលមានប្រយោជន៍ផ្សេងទៀត ដែលជ្រើសតាំងអ្នកតំណាងនោះ។

(២) [ ការតំណាងដោយបង្ខំ ]

(ក) ភាគីហត្ថលេខីអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំ ម្ចាស់ ឬ បុគ្គលមានប្រយោជន៍ផ្សេងទៀត ជ្រើសតាំងអ្នកតំណាងសម្រាប់គោលបំណងនីតិវិធីចំពោះមុខការិយាល័យ លើកលែងតែអ្នកទទួលសិទ្ធិនៃ សំណុំលិខិតស្នើសុំ អ្នកដាក់ពាក្យសុំ ម្ចាស់ ឬបុគ្គលមានប្រយោជន៍ផ្សេងទៀត អាចធ្វើដោយខ្លួនផ្ទាល់ចំពោះមុខការិយាល័យសម្រាប់នីតិវិធីដូចខាងក្រោម:

(i) ការដាក់សំណុំលិខិតស្នើសុំសម្រាប់គោលបំណងកាលបរិច្ឆេទនៃការសុំចុះបញ្ជី

(ii) ការបង់កម្រៃធម្មតា

(iii) នីតិវិធីផ្សេងទៀតដូចកំណត់ក្នុងបទបញ្ជា

(iv) ការចេញបង្កាន់ដៃ ឬសេចក្ដីជូនដំណឹងដោយការិយាល័យចំពោះនីតិវិធីដូចមានចែងក្នុងចំនុច(i)ដល់(iii)។

(ខ) កម្រៃរក្សាសិទ្ធិ អាចបង់ដោយបុគ្គលណាមួយ។

(៣) [ ការជ្រើសតាំងអ្នកតំណាង ]

ភាគីហត្ថលេខី ត្រូវទទួលស្គាល់ការជ្រើសតាំងអ្នកតំណាងដែលបានដាក់នៅការិយាល័យតាមរបៀបដែលកំណត់ដោយបទបញ្ជា។

(៤) [ ការហាមឃាត់លក្ខខណ្ឌតម្រូវផ្សេងទៀត ]

គ្មានភាគីហត្ថលេខីណា អាចតម្រូវឱ្យបំពេញលក្ខខណ្ឌទម្រង់ផ្សេងពីលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌទី(១)ដល់ទី(៣) ចំពោះបញ្ហាទាំងឡាយដែលពាក់ព័ន្ធក្នុងកថាខណ្ឌទាំងនេះ លើកលែងតែសន្ធិសញ្ញានេះឬ បទបញ្ជាចែងផ្សេង។

(៥) [ ការជូនដំណឹង ]

នៅពេលដែលមិនបានបំពេញលក្ខខណ្ឌណាមួយដែលទាមទារដោយភាគីហត្ថលេខីតាមកថាខណ្ឌទី(១)ដល់ទី(៣) ការិយាល័យត្រូវជូនដំណឹងដល់អ្នកទទួលសិទ្ធិនៃសំណុំលិខិតស្នើសុំ អ្នកដាក់ពាក្យសុំ ម្ចាស់ ឬបុគ្គលមានប្រយោជន៍ផ្សេងទៀត ដោយផ្ដល់ឱកាសឱ្យបំពេញតាមលក្ខខណ្ឌនេះ និងដើម្បីធ្វើការសង្កេតតាមរយៈពេលដែលកំណត់ក្នុងបទបញ្ជា។

(៦) [ ការមិនបំពេញតាមលក្ខខណ្ឌ ]

នៅពេលដែលមិនបានបំពេញលក្ខខណ្ឌណាមួយ ដែលទាមទារដោយភាគីហត្ថលេខីតាមកថា

ខណ្ឌទី(១)ដល់ទី(៣) តាមរយៈពេលដែលកំណត់ក្នុងបទបញ្ញា ភាគីហត្ថលេខីអាចអនុវត្តទណ្ឌកម្មដូចមានចែងក្នុងច្បាប់របស់ខ្លួន។

## មាត្រា៨

## ព័ត៌មាន អាសយដ្ឋាន

(១) [ទម្រង់ និងមធ្យោបាយនៃការបញ្ជូនព័ត៌មាន]

(ក) លើកលែងតែការចុះកាលបរិច្ឆេទនៃការសុំចុះបញ្ជីក្នុងមាត្រា៥(១) និងលើកលែងតែមាត្រា៦(១) បទបញ្ញាត្រូវកំណត់ពីលក្ខខណ្ឌដែលភាគីហត្ថលេខីត្រូវបានអនុញ្ញាតឱ្យអនុវត្តទម្រង់និងមធ្យោបាយនៃការបញ្ជូនព័ត៌មាន លើកលែងតែអនុកថាខណ្ឌ(ខ) ដល់(ឃ) ។

(ខ) ភាគីហត្ថលេខីមិនតម្រូវឱ្យទទួលយកការដាក់ព័ត៌មានផ្សេងក្រៅពីទម្រង់ក្រដាសឡើយ។

(គ) ភាគីហត្ថលេខីមិនតម្រូវឱ្យបដិសេធការដាក់ព័ត៌មាន ដោយទម្រង់ក្រដាសឡើយ។

(ឃ) ភាគីហត្ថលេខីត្រូវទទួលយកការដាក់ព័ត៌មានដោយទម្រង់ក្រដាស់ ដើម្បីតម្រូវតាមរយៈពេល។

(២) [ភាសានៃព័ត៌មាន]

ភាគីហត្ថលេខី អាចតម្រូវឱ្យព័ត៌មានត្រូវធ្វើជាភាសាដែលទទួលយកដោយការិយាល័យ លើកលែងតែ សន្ធិសញ្ញានេះនិងបទបញ្ញាចែងផ្សេង។

(៣) [ ទម្រង់គំរូអន្តរជាតិ]

ថ្វីបើមានចែងក្នុងកថាខណ្ឌទី(១)(ក) និងលើកលែងតែកថាខណ្ឌទី(១)(ខ) និងមាត្រា៦(២)(ខ) ភាគីហត្ថលេខីត្រូវទទួលយកការបង្ហាញមាតិកាព័ត៌មានក្នុងទម្រង់ដែលដូចនឹងទម្រង់គំរូអន្តរជាតិចំពោះព័ត៌មានដែលមានចែងក្នុងបទបញ្ញា ប្រសិនបើមាន។

(៤) [ ការចុះហត្ថលេខាលើព័ត៌មាន ]

(ក) នៅពេលដែលភាគីហត្ថលេខីតម្រូវឱ្យមានហត្ថលេខាចំពោះព័ត៌មាន ភាគីហត្ថលេខីនេះត្រូវទទួលយកហត្ថលេខាណាដែលស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងបទបញ្ញា។

(ខ)ភាគីហត្ថលេខីណាមួយមិនអាចតម្រូវឱ្យមានការបញ្ជាក់ លិខិតសារការី យថាភាពនីត្យានុកូលកម្ម ឬការបញ្ជាក់ផ្សេងទៀតនៃហត្ថលេខា ដែលទាក់ទងទៅការិយាល័យ លើកលែងតែនីតិវិធី ដូចតុលាការ ឬ នីតិវិធីដែលកំណត់ក្នុងបទបញ្ញា។

(គ) លើកលែងតែអនុកថាខណ្ឌ(ខ) ភាគីហត្ថលេខីអាចតម្រូវឱ្យផ្តល់ភស្តុតាងដល់ការិយាល័យ តែនៅពេលដែលការិយាល័យសង្ស័យសមហេតុសមផលពីយថាភាពនៃហត្ថលេខា។

(៥) [ ការបង្ហាញក្នុងព័ត៌មាន ]

ភាគីហត្ថលេខីអាចតម្រូវថា ព័ត៌មានត្រូវបង្ហាញចំនុចមួយឬច្រើនដូចដែលបានកំណត់ក្នុងបទបញ្ញា។

(៦) [ អាសយដ្ឋានទាក់ទង អាសយដ្ឋានសម្រាប់សេវាកម្មច្បាប់ និងអាសយដ្ឋានផ្សេងទៀត ]

លើកលែងតែមានបទប្បញ្ញត្តិណាមួយកំណត់ក្នុងបទបញ្ជា ភាគីហត្ថលេខីអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំ ម្ចាស់ ឬបុគ្គលមានប្រយោជន៍ផ្សេងទៀត បង្ហាញក្នុងព័ត៌មាន នូវៈ

(i) អាសយដ្ឋានទាក់ទង

(ii) អាសយដ្ឋានសម្រាប់សេវាកម្មច្បាប់

(iii) អាសយដ្ឋានផ្សេងៗទៀតដែលមានចែងក្នុងបទបញ្ជា។

(៧) [ ការជូនដំណឹង]

នៅពេលដែលមិនបានបំពេញលក្ខខណ្ឌណាមួយចំពោះព័ត៌មានដែលទាមទារដោយភាគីហត្ថលេខីតាមកថាខណ្ឌទី(១)ដល់ ទី(៦) ការិយាល័យត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំ ម្ចាស់ ឬបុគ្គលមានប្រយោជន៍ផ្សេងទៀត ដោយផ្តល់ឱកាសឱ្យបំពេញតាមលក្ខខណ្ឌនេះ និងដើម្បីធ្វើការសង្កេតតាមរយៈពេលដែលកំណត់ក្នុងបទបញ្ជា។

(៨) [ការមិនបានបំពេញលក្ខខណ្ឌ ]

នៅពេលដែលមិនបានបំពេញលក្ខខណ្ឌណាមួយដែលទាមទារដោយភាគីហត្ថលេខី តាមកថាខណ្ឌទី(១)ដល់ ទី(៦) តាមរយៈពេលដែលកំណត់ក្នុងបទបញ្ជា ភាគីហត្ថលេខីអាចអនុវត្តទណ្ឌកម្មដូចមានចែងក្នុងច្បាប់របស់ខ្លួន លើកលែងតែមាត្រា៥និងមាត្រា១០និងការលើកលែងផ្សេងទៀតដូចបានកំណត់ក្នុងបទបញ្ជា។

## មាត្រា៩

## ការជូនដំណឹង

(១) [ ការជូនដំណឹងគ្រប់គ្រាន់ ]

ការជូនដំណឹងណាមួយក្នុងសន្ធិសញ្ញានេះឬបទបញ្ជាដែលផ្តល់ដោយការិយាល័យទៅអាសយដ្ឋានទាក់ទង ឬអាសយដ្ឋានសម្រាប់សេវាច្បាប់ដែលបានបង្ហាញក្នុងមាត្រា៨(៦) ឬ អាសយដ្ឋានផ្សេងទៀតដែលចែងក្នុងបទបញ្ជាក្នុងគោលបំណងនៃបទប្បញ្ញត្តិនេះ ហើយដែលអនុលោមតាមបទប្បញ្ញត្តិចំពោះការជូនដំណឹងនេះ ត្រូវចាត់ទុកថាជាការជូនដំណឹងគ្រប់គ្រាន់ក្នុងគោលបំណងនៃសន្ធិសញ្ញានេះ និងបទបញ្ជា។

(២) [ ការមិនបានផ្តល់ការបង្ហាញដែលអាចទាក់ទងបាន]

បទប្បញ្ញត្តិក្នុងសន្ធិសញ្ញានេះ និងក្នុងបទបញ្ជា មិនតម្រូវឱ្យភាគីហត្ថលេខីជូនដំណឹងដល់ អ្នកដាក់ពាក្យសុំ ម្ចាស់ ឬបុគ្គលមានប្រយោជន៍ផ្សេងទៀត ប្រសិនបើការបង្ហាញដែលអាចទាក់ទងទៅ អ្នកដាក់ពាក្យសុំ ម្ចាស់ ឬបុគ្គលដែលមានប្រយោជន៍ផ្សេងទៀត មិនបានដាក់ជូនការិយាល័យ។

(៣) [ ការមិនបានជូនដំណឹង ]

លើកលែងតែមាត្រា១០ ករណីការិយាល័យមិនបានជូនដំណឹងដល់អ្នកដាក់ពាក្យសុំ ម្ចាស់ ឬបុគ្គលមានប្រយោជន៍ផ្សេងទៀត ពីការមិនគោរពតាមលក្ខខណ្ឌណាមួយក្នុងសន្ធិសញ្ញានេះ ឬបទ

បញ្ហា អវត្តមាននៃការជូនដំណឹងនេះមិនមែនជាការដោះបន្ទុកចំពោះអ្នកដាក់ពាក្យសុំ ម្ចាស់ ឬបុគ្គលមានប្រយោជន៍ផ្សេងទៀត ពីកាតព្វកិច្ចគោរពតាមលក្ខខណ្ឌទាំងនេះឡើយ។

## មាត្រា១០

## សុពលភាពនៃប្រកាសនីយបត្រតក្កកម្ម ការលុបចោល

(១) [សុពលភាពនៃប្រកាសនីយបត្រក្កកម្មមិនត្រូវបានប៉ះពាល់ដោយការមិនគោរពតាមលក្ខខណ្ឌទម្រង់មួយចំនួន ]

ការមិនគោរពតាមលក្ខខណ្ឌទម្រង់ណាមួយដែលមានចែងក្នុងមាត្រា៦(១) (២) (៤) (៥)និងមាត្រា៨(១)ដល់(៤)ទាក់ទងនឹងសំណុំលិខិតស្នើសុំ មិនអាចជាមូលហេតុនៃការលុបចោលឬមោឃភាពប្រកាសនីយបត្រតក្កកម្មបានឡើយ ទោះទាំងស្រុងឬដោយផ្នែកក៏ដោយ លើកលែងតែការមិនគោរពតាមលក្ខខណ្ឌទម្រង់កើតឡើងដោយចេតនាក្លែងបន្លំ ។

(២) [ ឱកាសដើម្បីធ្វើការសង្កេត វិសោធនកម្ម ឬការកែតម្រូវ ក្នុងករណីមានចេតនាលុបចោលឬមោឃភាព]

ប្រកាសនីយបត្រតក្កកម្ម មិនអាចត្រូវបានលុបចោលឬធ្វើមោឃភាព ទោះទាំងស្រុងឬដោយផ្នែកក្តី ដោយគ្មានផ្តល់ឱកាសដល់ម្ចាស់ ដើម្បីធ្វើការសង្កេតពីចេតនាលុបចោលឬមោឃភាព និងដើម្បីធ្វើវិសោធនកម្មនិងកែតម្រូវ ដែលបានអនុញ្ញាតដោយច្បាប់ដែលអនុវត្ត តាមរយៈពេលមួយសមរម្យ។

(៣) [ គ្មានកាតព្វកិច្ចចំពោះនីតិវិធីពិសេស ]

កថាខណ្ឌទី(១)និងទី(២) មិនបង្កើតកាតព្វកិច្ច ឱ្យអនុវត្តនីតិវិធីតុលាការចំពោះការអនុវត្តន៍សិទ្ធិប្រកាសនីយបត្រតក្កកម្ម ផ្សេងពីកាតព្វកិច្ចក្នុងការអនុវត្តន៍ច្បាប់ទូទៅឡើយ។

## មាត្រា១១

## ការលើកលែងចំពោះរយៈពេល

(១) [ ការពន្យាររយៈពេល ]

ចំពោះរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា ភាគីហត្ថលេខីអាចចែងពីការពន្យាររយៈពេលដែលកំណត់ដោយការិយាល័យ លើសកម្មភាពក្នុងនីតិវិធីចំពោះមុខការិយាល័យទាក់ទងនឹង សំណុំលិខិតស្នើសុំឬប្រកាសនីយបត្រតក្កកម្ម ប្រសិនបើសំណើសុំនេះ ត្រូវធ្វើឡើយនៅការិយាល័យដោយអនុលោមតាមលក្ខខណ្ឌដែលបានកំណត់ក្នុងបទបញ្ជា ហើយប្រសិនបើសំណើនេះត្រូវបានដាក់ ជាជម្រើសរបស់ភាគីហត្ថលេខី:

(i) មុនផុតកំណត់រយៈពេល ឬ

(ii) បន្ទាប់ពីផុតកំណត់រយៈពេល និងតាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា។

(២) [ ការបន្តនីតិវិធី ]

នៅពេលដែលអ្នកដាក់ពាក្យសុំ ឬម្ចាស់ មិនបានគោរពតាមរយៈពេលដែលបានកំណត់ដោយ

ការិយាល័យនៃភាគីហត្ថលេខី លើសកម្មភាពក្នុងនីតិវិធីចំពោះមុខការិយាល័យទាក់ទងនឹង សំណុំលិខិតស្នើសុំ ឬប្រកាសនីយបត្រតក្កកម្ម ហើយភាគីហត្ថលេខីនេះមិនបានចែងពីការពន្យាររយៈពេលក្នុងកថាខណ្ឌទី(១)(ii) ភាគីហត្ថលេខីត្រូវចែងពីការបន្តនីតិវិធីចំពោះសំណុំលិខិតស្នើសុំឬប្រកាសនីយបត្រតក្កកម្ម ហើយប្រសិនបើចាំបាច់ ចែងអំពីការផ្តល់សិទ្ធិឡើងវិញដល់អ្នកដាក់ពាក្យសុំឬម្ចាស់ចំពោះសំណុំលិខិតស្នើសុំឬប្រកាសនីយបត្រតក្កកម្មនេះ ប្រសិនបើ:

(i) សំណើនេះ ត្រូវធ្វើឡើងនៅការិយាល័យដោយអនុលោមតាមលក្ខខណ្ឌដែលបានកំណត់ក្នុងបទបញ្ញា

(ii) សំណើត្រូវបានដាក់ និងបានបំពេញរាល់លក្ខខណ្ឌក្នុងរយៈពេលកម្រិត ចំពោះសកម្មភាពពាក់ព័ន្ធ តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ញា។

(៣) [ ការលើកលែង ]

ភាគីហត្ថលេខី មិនតម្រូវឱ្យចែងពីការលើកលែងដែលមានចែងក្នុងកថាខណ្ឌទី(១) ឬទី(២) ចំពោះការលើកលែងទាំងឡាយដែលបានកំណត់ក្នុងបទបញ្ញា។

(៤) [ កម្រៃ ]

ភាគីហត្ថលេខីអាចតម្រូវឱ្យបង់កម្រៃចំពោះសំណើក្នុងកថាខណ្ឌទី(១)ឬទី(២)។

(៥) [ ការហាមឃាត់លក្ខខណ្ឌផ្សេងទៀត ]

ភាគីហត្ថលេខី មិនតម្រូវឱ្យមគោរពលក្ខខណ្ឌផ្សេងក្រៅពីលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌទី(១)ដល់ទី(៤) ចំពោះការលើកលែងដែលមានចែងក្នុងកថាខណ្ឌទី(១)ឬទី(២) លើកលែងតែមានចែងផ្សេងក្នុងសន្ធិសញ្ញានេះ ឬក្នុងបទបញ្ញា។

(៦) [ ឱកាសដើម្បីធ្វើការសង្កេត ក្នុងករណីមានការបដិសេធ]

សំណើក្នុងកថាខណ្ឌទី(១)ឬទី(២) មិនត្រូវបដិសេធដោយគ្មានផ្តល់ឱកាសដល់អ្នកដាក់ពាក្យសុំ ឬម្ចាស់ ដើម្បីធ្វើការសង្កេតលើការបដិសេធ ក្នុងរយៈពេលមួយសមរម្យ។

## មាត្រា១២

## ការផ្តល់សិទ្ធិឡើងវិញបន្ទាប់ពីឃើញមានការយកចិត្តទុកដាក់ត្រឹមត្រូវ ឬ អចេតនាដោយការិយាល័យ

(១) [ សំណើ ]

នៅពេលដែលអ្នកដាក់ពាក្យសុំ ឬម្ចាស់ មិនបានគោរពតាមរយៈពេល លើសកម្មភាពក្នុងនីតិវិធីចំពោះមុខការិយាល័យ ហើយការមិនគោរពតាមនេះបង្កើតជាវិបាកផ្ទាល់ដែលធ្វើឱ្យបាត់បង់សិទ្ធិចំពោះសុំណុំលិខិតស្នើសុំឬប្រកាសនីយបត្រតក្កកម្ម ភាគីហត្ថលេខីត្រូវចែងថា ការិយាល័យត្រូវផ្តល់សិទ្ធិឡើងវិញដល់អ្នកដាក់ពាក្យសុំ ឬម្ចាស់ ចំពោះសំណុំលិខិតស្នើសុំឬប្រកាសនីយបត្រតក្កកម្មពាក់ព័ន្ធ ប្រសិនបើ:

(i) សំណើត្រូវធ្វើឡើងនៅការិយាល័យ ដោយអនុលោមតាមលក្ខខណ្ឌដែលបានកំណត់ក្នុងបទបញ្ញា

(ii) សំណើបានដាក់ និងបានបំពេញរាល់លក្ខខណ្ឌក្នុងរយៈពេលកម្រិត ចំពោះសកម្មភាពពាក់ព័ន្ធ តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា។

(iii) សំណើបានបញ្ជាក់ពីមូលហេតុនៃការមិនបានគោរពតាមរយៈពេល

(iv) ការិយាល័យយល់ឃើញថា ការមិនបានគោរពតាមរយៈពេល បានកើតឡើង ទោះបីបើកាលៈទេសៈបង្ហាញថា មានការយកចិត្តទុកដាក់ត្រឹមត្រូវក៏ដោយ ឬជាជម្រើសរបស់ភាគីហត្ថលេខី យល់ឃើញថា ការពន្យាណាមួយនេះកើតឡើងដោយអចេតនា។

(២) [ ការលើកលែង ]

ភាគីហត្ថលេខីមិនតម្រូវឱ្យចែងពីការផ្ដល់សិទ្ធិឡើងវិញក្នុងកថាខណ្ឌទី(១) ចំពោះការលើកលែងដែលបានកំណត់ក្នុងបទបញ្ជា។

(៣) [ កម្រៃ ]

ភាគីហត្ថលេខីអាចតម្រូវឱ្យបង់កម្រៃចំពោះសំណើក្នុងកថាខណ្ឌទី(១)។

(៤) [ ភស្តុតាង]

ភាគីហត្ថលេខីអាចតម្រូវថា សេចក្ដីអះអាង ឬភស្តុតាងផ្សេងៗទៀតដែលគាំទ្រមូលហេតុដែលមានចែងក្នុងកថាខណ្ឌទី(១)(iii) ត្រូវដាក់នៅការិយាល័យតាមរយៈពេលដែលកំណត់ដោយការិយាល័យ។

(៥) [ ឱកាសដើម្បីធ្វើការសង្កេតក្នុងករណីមានការបដិសេធ]

សំណើក្នុងកថាខណ្ឌទី(១) មិនត្រូវបដិសេធ ទោះទាំងមូល ឬដោយផ្នែកក្ដី ដោយគ្មាន ផ្ដល់ឱកាសដល់ភាគីដែលស្នើ ដើម្បីធ្វើការសង្កេតលើការបដិសេធ ក្នុងរយៈពេលមួយសមរម្យ។

## មាត្រា១៣

## ការកែតម្រូវ ឬ ការបន្ថែមសេចក្ដីអះអាងអាទិភាព ការផ្ដល់សិទ្ធិអាទិភាពឡើងវិញ

(១) [ ការកែតម្រូវ ឬការបន្ថែមសេចក្ដីអះអាងអាទិភាព ]

លើកលែងតែមានចែងផ្សេងក្នុងបទបញ្ជា ភាគីហត្ថលេខីអាចចែងពីការកែតម្រូវ ឬការបន្ថែមសេចក្ដីអះអាងអាទិភាពចំពោះសំណុំលិខិតស្នើសុំ(សំណុំលិខិតស្នើសុំបន្ទាប់) ប្រសិនបើៈ

(i) សំណើត្រូវធ្វើឡើងនៅការិយាល័យដោយអនុលោមតាមលក្ខខណ្ឌដែលបានកំណត់ក្នុងបទបញ្ជា

(ii) សំណើត្រូវបានដាក់តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា និង

(iii) កាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំបន្ទាប់ មិនយឺតជាងកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលអាទិភាព ដោយរាប់ចាប់ពីកាលបរិចេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំដំបូងដែលបានអះអាងអាទិភាព។

(២) [ ការពន្យារការដាក់សំណុំលិខិតស្នើសុំបន្ទាប់ ]

ដោយពិចារណាលើមាត្រា១៥ នៅពេលដែលសំណុំលិខិតស្នើសុំ(សំណុំលិខិតស្នើសុំបន្ទាប់)

ដែលអះអាង ឬអាចអះអាងអាទិភាពនៃសំណុំលិខិតស្នើសុំដំបូងដែលមានកាលបរិច្ឆេទនៃការសុំចុះបញ្ជីក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលអាទិភាព ប៉ុន្តែក្នុងរយៈពេលដែលបាន កំណត់ក្នុងបទបញ្ជា ភាគីហត្ថលេខីអាចចែងថា ការិយាល័យត្រូវផ្តល់សិទ្ធិអាទិភាពឡើងវិញ ប្រសិនបើៈ

(i) សំណើត្រូវធ្វើឡើងនៅការិយាល័យដោយអនុលោមតាមលក្ខខណ្ឌដែលបានកំណត់ក្នុងបទបញ្ជា

(ii) សំណើត្រូវបានដាក់តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា

(iii) សំណើបានបញ្ជាក់ពីមូលហេតុនៃការមិនអនុលោមតាមរយៈពេលអាទិភាព និង

(iv) ការិយាល័យយល់ឃើញថា ការមិនបានដាក់សំណុំលិខិតស្នើសុំបន្ទាប់ក្នុងរយៈពេលអាទិភាព បានកើតឡើង ទោះបីបើកាលៈទេសៈបង្ហាញថា មានការយកចិត្តទុកដាក់ត្រឹមត្រូវក៏ដោយ ឬជាជម្រើសរបស់ភាគីហត្ថលេខី ធ្វើឡើងដោយអចេតនា។

(៣) [ ការមិនបានដាក់ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំមុន ]

នៅពេលដែលច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំមុនដែលតម្រូវក្នុងមាត្រា៦(៥) មិនបានដាក់នៅការិយាល័យតាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជាស្របនឹងមាត្រា៦ ភាគីហត្ថលេខីត្រូវចែងថា ការិយាល័យអាចផ្តល់សិទ្ធិអាទិភាពឡើងវិញ ប្រសិនបើៈ

(i) សំណើត្រូវបានធ្វើឡើងនៅការិយាល័យដោយអនុលោមតាមលក្ខខណ្ឌដែលបា កំណត់ក្នុងបទបញ្ជា

(ii) សំណើត្រូវបានដាក់តាមរយៈពេលសម្រាប់ការដាក់ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំមុនដែលបានកំណត់ក្នុងបទបញ្ជាស្របនឹងមាត្រា៦(៥)

(iii) ការិយាល័យយល់ឃើញថា សំណើឱ្យផ្តល់ច្បាប់ចម្លងត្រូវបានដាក់នៅការិយាល័យដែលសំណុំលិខិតស្នើសុំមុនបានដាក់ តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជាហើយ

(iv) ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំមុនត្រូវបានដាក់តាមរយៈពេលដែលបានកំណត់ក្នុងបទបញ្ជា។

(៤) [ កម្រៃ ]

ភាគីហត្ថលេខីអាចតម្រូវឱ្យបង់កម្រៃចំពោះសំណើក្នុងកថាខណ្ឌទី(១)ដល់ទី(៣)។

(៥) [ ភស្តុតាង ]

ភាគីហត្ថលេខីអាចតម្រូវថា សេចក្តីអះអាង ឬភស្តុតាងផ្សេងៗទៀតដែលគាំទ្រមូលហេតុដែលមានចែងក្នុងកថាខណ្ឌទី(២)(iii) ត្រូវដាក់នៅការិយាល័យតាមរយៈពេលដែលកំណត់ដោយការិយាល័យ។

(៦) [ ឱកាសដើម្បីធ្វើការសង្កេតក្នុងករណីមានការបដិសេធ]

សំណើក្នុងកថាខណ្ឌទី(១)ដល់ទី(៣) មិនត្រូវបដិសេធ ទោះទាំងមូល ឬដោយផ្នែកក្តី ដោយ

គ្មានផ្តល់ឱកាសដល់ភាគីដែលស្នើ ដើម្បីធ្វើការសង្កេតលើការបដិសេធ ក្នុងរយៈពេលមួយសមរម្យ។

## មាត្រា១៤

## បទបញ្ជា

(១) [ មាតិកា ]

(ក) បទបញ្ជាដែលជាឧបសម្ព័ន្ធនាំសន្ធិសញ្ញានេះ ចែងពីប្រការពាក់ព័ន្ធនឹងៈ

(i) បញ្ហាដែលសន្ធិសញ្ញានេះចែងច្បាស់លាស់ ត្រូវកំណត់ក្នុងបទបញ្ជា

(ii) សេចក្តីលម្អិតដែលមានប្រយោជន៍ក្នុងការអនុវត្តន៍បទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ

(iii) លក្ខខណ្ឌរដ្ឋបាល បញ្ហារដ្ឋបាល ឬ នីតិវិធីរដ្ឋបាល។

(ខ) បទបញ្ជាក៏ចែងពីប្រការដែលពាក់ព័ន្ធនឹងលក្ខខណ្ឌទម្រង់ ដែលភាគីហត្ថលេខីត្រូវបានអនុញ្ញាតឱ្យអនុវត្តចំពោះសំណើសម្រាប់ៈ

(i) ការកត់ត្រាការផ្លាស់ប្តូរឈ្មោះ ឬអាសយដ្ឋាន

(ii) ការកត់ត្រាការផ្លាស់ប្តូរអ្នកដាក់ពាក្យសុំឬម្ចាស់

(iii) ការកត់ត្រាអាជ្ញាប័ណ្ណឬ ប្រាតិភោគភណ្ឌិក

(iv) ការកែតម្រូវកំហុស។

(គ) បទបញ្ជាក៏ចែងផងដែរពីការបង្កើតទម្រង់គំរូអន្តរជាតិ និងការបង្កើតទម្រង់ពាក្យសុំក្នុងគោលបំណងអនុវត្តមាត្រា៦(២)(ខ) ដោយសន្និបាត ដោយមានជំនួយពីការិយាល័យអន្តរជាតិ។

(២) [ វិសោធនកម្មបទបញ្ជា ]

លើកលែងតែកថាខណ្ឌទី(៣) វិសោធនកម្មបទបញ្ជាណាមួយអាចធ្វើទៅបានដោយមានសំលេង៣/៤(បីភាគបួន)នៃសំលេងឆ្នោតដែលបានបោះ។

(៣) [ ការតម្រូវឱ្យមានសំលេងឯកច្ឆ័ន ]

(ក) បទបញ្ជាអាចកំណត់ជាក់លាក់នូវបទប្បញ្ញត្តិណា ដែលត្រូវធ្វើវិសោធនកម្មដោយឯកច្ឆ័ន។

(ខ) វិសោធនកម្មបទបញ្ជាណាមួយដែលបន្ថែមបទប្បញ្ញត្តិ ឬលុបបទប្បញ្ញត្តិពីបទប្បញ្ញត្តិដែលមានចែងជាក់លាក់ក្នុងបទបញ្ជាតាមអនុកថាខណ្ឌ(ក) ត្រូវតម្រូវឱ្យមានសំលេងឯកច្ឆ័ន។

(គ) ដើម្បីកំណត់សំលេងឯកច្ឆ័ន គេត្រូវពិចារណាតែលើសំលេងឆ្នោតដែលបានបោះពិតប្រាកដប៉ុណ្ណោះ។ អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ។

(៤) [ វិវាទរវាងសន្ធិសញ្ញានិងបទបញ្ជា ]

ក្នុងករណីមានវិវាទរវាងបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះនិងបទបញ្ជា បទប្បញ្ញត្តិនៃសន្ធិសញ្ញាត្រូវយកជាគោល។

## មាត្រា១៥
## ទំនាក់ទំនងជាមួយអនុសញ្ញាទីក្រុងប៉ារីស

(១) [ កាតព្វកិច្ចអនុលោមតាមអនុសញ្ញាទីក្រុងប៉ារីស ]

ភាគីហត្ថលេខីនីមួយៗត្រូវគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញាទីក្រុងប៉ារីសដែលពាក់ព័ន្ធនឹងប្រកាសនីយបត្រតក្កកម្ម។

(២) [ កាតព្វកិច្ចនិងសិទ្ធិក្នុងអនុសញ្ញាទីក្រុងប៉ារីស ]

(ក) គ្មាបទប្បញ្ញត្តិណាក្នុងសន្ធិសញ្ញានេះ ធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចដែលភាគីហត្ថលេខីមានចំពោះគ្នាក្នុងអនុសញ្ញាទីក្រុងប៉ារីស។

(ខ) គ្មានបទប្បញ្ញត្តិណាក្នុងសន្ធិសញ្ញានេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនៃអ្នកដាក់ពាក្យសុំនិងម្ចាស់ ដែលទទួលបានក្នុងអនុសញ្ញាទីក្រុងប៉ារីស។

## មាត្រា១៦
## អានុភាពនៃការកែប្រែ វិសោធនកម្ម និងការផ្លាស់ប្តូរសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

(១) [ការអនុវត្តបាននៃការកែប្រែ វិសោធនកម្ម និងការផ្លាស់ប្តូសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ]

លើកលែងតែកថាខណ្ឌទី(២) ការកែប្រែ វិសោធនកម្ម ឬការផ្លាស់ប្តូរ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មដែលធ្វើឡើងក្រោយ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០០ ដែលអនុលោមតាមមាត្រាទាំងឡាយនៃសន្ធិសញ្ញានេះ ត្រូវយកមកអនុវត្ត ក្នុងគោលបំណងនៃសន្ធិសញ្ញានេះនិងបទបញ្ជាប្រសិនបើ សន្និបាតសម្រេចដូច្នេះ ក្នុងករណីពិសេស ត្រូវធ្វើឡើយដោយសំលេង៣/៤(បីភាគបួន)នៃសំលេងឆ្នោតដែលបានបោះ។

(២) [ការមិនអនុវត្តបាននូវបទប្បញ្ញត្តិអន្តរកាលនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ]

បទប្បញ្ញត្តិណាមួយនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដោយសារបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះបានការកែប្រែ វិសោធនកម្ម ឬផ្លាស់ប្តូរ ដែលមិនអនុវត្តបានចំពោះរដ្ឋជាភាគីឬចំពោះការិយាល័យនៃរដ្ឋ ឬតំណាងរដ្ឋនេះ ដោយហេតុថាបទប្បញ្ញត្តិក្រោយនេះមិនស្របនឹងច្បាប់ដែលអនុវត្តដោយរដ្ឋឬការិយាល័យនេះ មិនត្រូវអនុវត្តឡើយ ក្នុងគោលបំណងនៃសន្ធិសញ្ញានេះនិងបទបញ្ជា។

## មាត្រា១៧
## សន្និបាត

(១) [ សមាសភាព ]

(ក) ភាគីហត្ថលេខីទាំអស់ត្រូវមានសន្និបាតមួយ។

(ខ) ភាគីហត្ថលេខីនីមួយៗ ត្រូវតំណាងដោយប្រតិភូម្នាក់ដែលអាចអមដោយប្រតិភូស្តីទី ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន ក្នុងសន្និបាត។ ប្រតិភូនីមួយៗអាចជាតំណាងឱ្យភាគីហត្ថលេខីមួយតែប៉ុណ្ណោះ។

(២) [ ការងារ ]

សន្និបាតត្រូវៈ

(i) ពិភាក្សារាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការរក្សានិងការអភិវឌ្ឍន៍នៃសន្ធិសញ្ញានេះ និងការអនុវត្តន៍និងការប្រព្រឹត្តទៅនៃសន្ធិសញ្ញានេះ។

(ii) បង្កើតទម្រង់គំរូអន្តរជាតិនិងទម្រង់ពាក្យសុំ ដែលមានចែងក្នុងមាត្រា១៤(១)(គ) ដោយមានជំនួយពីការិយាល័យអន្តរជាតិ

(iii) ធ្វើវិសោធនកម្មបទបញ្ជា

(iv) កំណត់លក្ខខណ្ឌសម្រាប់កាលបរិច្ឆេទសំណុំលិខិតស្នើសុំនៃទម្រង់គំរូអន្តរជាតិនីមួយៗ និងទម្រង់ពាក្យសុំ ដូចមានចែងក្នុងចំនុច (ii) និងវិសោធនកម្មនីមួយៗដូចមានចែងក្នុង ចំនុច(iii)

(v) តាមមាត្រា១៦(១) សម្រេចថាតើ ការកែប្រែ វិសោធនកម្ម ឬការផ្លាស់ប្តូរសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ត្រូវយកមកអនុវត្តបាន ក្នុងគោលបំណងនៃសន្ធិសញ្ញានេះនិងបទបញ្ជា

(vi) បំពេញមុខងារផ្សេងទៀតដែលស្របតាមសន្ធិសញ្ញានេះ។

(៣) [ កូរ៉ុម ]

(ក) កូរ៉ុមនៃសន្និបាតត្រូវមានចំនួនពាក់កណ្តាល់នៃសមាជិកសន្និបាតដែលជារដ្ឋ។

(ខ) ថ្វីបើមានចែងក្នុងអនុកថាខណ្ឌ(ក)ក៏ដោយ ក្នុងសម័យប្រជុំនីមួយៗ ប្រសិនបើចំនួនសមាជិកសន្និបាតដែលជារដ្ឋ មានតំណាងតិចជាង១/២(មួយភាគពីរ) ប៉ុន្តែមានចំនួនស្មើឬច្រើនជាង ១/៣(មួយភាគបី) សន្និបាតអាចធ្វើសេចក្តីសម្រេចបាន ប៉ុន្តែសេចក្តីសម្រេចទាំងនេះ មានអានុភាពអនុវត្ត តែក្នុងករណីដែលបានបំពេញលក្ខខណ្ឌកំណត់ដូចខាងក្រោម លើកលែងតែសេចក្តីសម្រេចនោះទាក់ទងនឹងនីតិវិធីរបស់សន្និបាតផ្ទាល់។ ការិយាល័យអន្តរជាតិត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះ ទៅសមាជិកសន្និបាតដែលជារដ្ឋដែលអវត្តមាន និងត្រូវអញ្ជើញសមាជិកទាំងនេះ ឱ្យបោះឆ្នោតជាលាយលក្ខណ៍អក្សរឬបោះឆ្នោតអនុប្បវាទ ក្នុងរយៈពេល៣(បី)ខែចាប់ពីថ្ងៃជូនដំណឹង។ បើផុតរយៈពេលនេះ ប្រសិនបើ ចំនួននៃសមាជិកដែលបានបោះឆ្នោតឬបោះឆ្នោតអនុបវាទ ស្មើនឹងចំនួនសមាជិកដែលខ្វះ សម្រាប់កូរ៉ុមក្នុងសម័យប្រជុំ សេចក្តីសម្រេចនេះនឹងមានអនុភាពអនុវត្ត ឱ្យតែនៅពេលនោះបានគ្រប់សំលេងភាគច្រើនដែលត្រូវការ ។

(៤) [ ការធ្វើសេចក្តីសម្រេចក្នុងសន្និបាត]

(ក) សន្ទបាតត្រូវព្យាយាមសម្រេចសេចក្តីដោយឯកច្ឆ័ន្ទ។

(ខ) នៅពេលដែលសេចក្តីសម្រេចចិត្តមិនអាចធ្វើដោយឯកច្ឆ័ន្ទបានទេ បញ្ហានេះត្រូវសម្រេចដោយការបោះឆ្នោត។ ក្នុងករណីនេះ:

(i) ភាគីហត្ថលេខីនីមួយៗដែលជារដ្ឋ ត្រូវមានសំលេងឆ្នោតតែមួយ និងត្រូវបោះឆ្នោតតែក្នុងនាមខ្លួនផ្ទាល់ ហើយ

(ii) ភាគីហត្ថលេខីណាមួយដែលជាអង្គការអន្តររដ្ឋាភិបាល អាចចូលរួមក្នុងការបោះឆ្នោត ជំនួសសមាជិកជារដ្ឋរបស់ខ្លួន ដោយមានចំនួនសំលេងឆ្នោតស្មើនឹងចំនួនសមាជិកជារដ្ឋរបស់ខ្លួនដែលជាភាគីសន្ធិសញ្ញានេះ។ គ្មានអង្គការអន្តររដ្ឋា ភិបាលណាអាចចូលរួមក្នុងការបោះឆ្នោត ប្រសិនបើសមាជិកណាមួយដែលជារដ្ឋសមាជិករបស់ខ្លួនបានអនុវត្តសិទ្ធិបោះឆ្នោត ហើយបើសមាជិណាមួយនៃអង្គការអន្តររដ្ឋាភិបាលនេះ មិនបានអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនទេ អង្គការនេះអាចអនុវត្តសិទ្ធិបោះឆ្នោតរបស់សមាជិករបស់ខ្លួនបាន។ ជាងនេះទៅទៀត អង្គការអន្តររដ្ឋាភិបាលនេះ មិនត្រូវចូលរួមក្នុងការបោះឆ្នោត ប្រសិនបើសមាជិកណាមួយនៃរដ្ឋជាសមាជិករបស់ខ្លួន ដែលជាភាគីសន្ធិសញ្ញានេះ ជារដ្ឋសមាជិកនៃអង្គការអន្តររដ្ឋាភិបាលមួយផ្សេងទៀត ហើយអង្គការអន្តររដ្ឋាភិបាលផ្សេងនេះបានចូលរួមក្នុងការបោះឆ្នោតនេះ។

(៥) [ សំលេងភាគច្រើន ]

(ក) លើកលែងតែមាត្រា១៤(២)និង(៣) មាត្រា១៦(១)និងមាត្រា១៩(៣) សេចក្តីសម្រេចទាំងឡាយរបស់សន្និបាតទាមទារឱ្យមានសំលេង២/៣(ពីរភាគបី) នៃសំលេងឆ្នោតដែលបានបោះ។

(ខ) ដើម្បីកំណត់សំលេងភាគច្រើន គេត្រូវពិចារណាតែលើសំលេងឆ្នោតដែលបានបោះពិតប្រាកដប៉ុណ្ណោះ។ អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ។

(៦) [ កិច្ចប្រជុំ ]

សន្និបាតត្រូវប្រជុំសាមញ្ញរៀងរាល់ពីរឆ្នាំម្តង តាមការកោះប្រជុំដោយអគ្គនាយក។

(៧) [ បទបញ្ជាផ្ទៃក្នុង ]

សន្និបាតត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន រួមទាំងវិធានសម្រាប់កោះប្រជុំវិសាមញ្ញ។

## មាត្រា១៨

## ការិយាល័យអន្តរជាតិ

(១) [ កិច្ចការរដ្ឋបាល ]

(ក) ការិយាល័យអន្តរជាតិត្រូវអនុវត្តកិច្ចការរដ្ឋបាលដែលទាក់ទងនឹងសន្ធិសញ្ញានេះ។

(ខ) ជាពិសេស ការិយាល័យអន្តរជាតិត្រូវរៀបចំកិច្ចប្រជុំ និងត្រូវបំពេញការងារជាលេខា

ធិការដ្ឋាននៃសន្និបាតនិងនៃគណៈកម្មាធិការជំនាញនិងក្រុមការងារដែលបង្កើតឡើងដោយសន្និបាត។

(២) [ កិច្ចប្រជុំក្រៅពីកិច្ចប្រជុំសន្និបាត ]

អគ្គនាយក ត្រូវកោះប្រជុំគណៈកម្មាធិការនិងក្រុមការងារណាមួយដែលបង្កើតឡើងដោយសន្និបាត។

(៣) [ តួនាទីការិយាល័យអន្តរជាតិក្នុងកិច្ចប្រជុំសន្និបាតនិងកិច្ចប្រជុំផ្សេងទៀត ]

(ក) អគ្គនាយកនិងបុគ្គលដែលចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមរាល់កិច្ចប្រជុំទាំងអស់របស់ សន្និបាត គណៈកម្មាធិការ និងក្រុមការងារដែលបង្កើតឡើងដោយសន្និបាត តែគ្មានសិទ្ធិបោះឆ្នោតទេ។

(ខ) អគ្គនាយកឬបុគ្គលិកណាម្នាក់ដែលចាត់តាំងដោយអគ្គនាយក ត្រូវជាលេខាដោយស្វ័យប្រវត្តិរបស់សន្និបាត និងរបស់គណៈកម្មាធិការនិងក្រុមការងារដែលមានចែងក្នុងអនុកថាខណ្ឌ (ក)។

(៤) [ សន្និសីទ ]

(ក) តាមការណែនាំរបស់សន្និបាត ការិយាល័យអន្តរជាតិត្រូវរៀបឱ្យមានចំសន្និសីទកែប្រែ។

(ខ) ការិយាល័យអន្តរជាតិអាចពិគ្រោះយោបល់ជាមួយរដ្ឋជាសមាជិកនៃអង្គការ អង្គការអន្តរ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនិងជាតិ ទាក់ទងនឹងការរៀបចំនេះ។

(គ) អគ្គនាយក និង បុគ្គលដែលចាត់តាំងដោយអគ្គនាយកត្រូវចូលរួមក្នុងកិច្ចពិភាក្សាក្នុងសន្និ សីទកែប្រែ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតទេ។

(៥) [ ការងារផ្សេងៗ ]

ការិយាល័យអន្តរជាតិត្រូវបំពេញការងារផ្សេងៗទៀត ដែលបានប្រគល់ឱ្យដោយសន្និសញ្ញានេះ។

## មាត្រា១៩
## ការកែប្រែ

(១) [ ការកែប្រែសន្និសញ្ញា ]

លើកលែងតែកថាខណ្ឌទី(២) សន្និសញ្ញានេះអាចត្រូវបានកែប្រែដោយសន្និសីទនៃភាគីហត្ថលេខី។ ការកោះប្រជុំសន្និសីទកែប្រែណាមួយ ត្រូវសម្រេចដោយសន្និបាត។

(២) [ ការកែប្រែ ឬវិសោធនកម្មបទប្បញ្ញត្តិមួយចំនួននៃសន្និសញ្ញា ]

មាត្រា១៧(២)និង(៦) អាចត្រូវបានធ្វើវិសោធនកម្មដោយសន្និសីទកែប្រែ ឬដោយសន្និបាតតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី(៣)។

(៣) [ វិសោធនកម្មបទប្បញ្ញត្តិមួយចំនួននៃសន្និសញ្ញាដោយសន្និបាត ]

(ក) សំណើធ្វើវិសោធនកម្មដោយសន្និបាតតាមមាត្រា១៧(២)និង(៦) អាចផ្តួចផ្តើម

ដោយភាគីហត្ថលេខីឬដោយអគ្គនាយក។ យ៉ាងហោចណាស់៦(ប្រាំមួយ)ខែមុនសន្និបាតលើកយកមកពិចារណា អគ្គនាយកត្រូវទាក់ទងទៅភាគីហត្ថលេខីអំពីសំណើនេះ ។

(ខ) ការអនុម័តវិសោធនកម្មណាមួយនៃបទប្បញ្ញត្តិដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ទាមទារឱ្យមានសំលេង ៣/៤(បីភាគបួន)នៃសំលេងឆ្នោតដែលបានបោះ។

(គ) វិសោធនកម្មណាមួយនៃបទប្បញ្ញត្តិដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ត្រូវចូលជាធរមាន១(មួយ)ខែបន្ទាប់ពីអគ្គនាយកទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលបានធ្វើឡើង ដោយភាគីហត្ថលេខី៣/៤(បីភាគបួន) ដែលជាសមាជិកសន្និបាតដោយស្របតាមរដ្ឋធម្មនុញ្ញរបស់ខ្លួននៅពេលអនុម័តវិសោធនកម្មនេះ។ វិសោធនកម្មបទប្បញ្ញត្តិទាំងនេះហើយដែលត្រូវបានទទួលយក មានអានុភាពចងភាគីហត្ថលេខីទាំងអស់នៅពេលដែលវិសោធនកម្មនេះចូលជាធរមាន និង ចងរដ្ឋនិងអង្គការអន្តររដ្ឋាភិ បាលដែលក្លាយជាភាគីហត្ថលេខីតាមកាលបរិច្ឆេទបន្ទាប់។

## មាត្រា២០

## ការក្លាយជាភាគីនៃសន្ធិសញ្ញា

(១) [ រដ្ឋ ]

រដ្ឋណាមួយដែលជាភាគីអនុសញ្ញាទីក្រុងប៉ារីសឬជាសមាជិកអង្គការ ហើយនៅពេលដែលប្រកាសនីយបត្រតក្កកម្មអាចផ្តល់ តាមរយៈការិយាល័យរដ្ឋផ្ទាល់ ឬតាមរយៈការិយាល័យរដ្ឋមួយផ្សេងទៀត ឬតាមរយៈអង្គការអន្តររដ្ឋាភិបាល អាចក្លាយជាភាគីនៃសន្ធិសញ្ញានេះបាន។

(២) [ អង្គការអន្តររដ្ឋាភិបាល ]

អង្គការអន្តររដ្ឋាភិបាលណាមួយអាចក្លាយជាភាគីសន្ធិសញ្ញានេះ ប្រសិនបើយ៉ាងហោចណាស់រដ្ឋជាសមាជិកមួយនៃអង្គការអន្តររដ្ឋាភិបាលនេះជាភាគីអនុសញ្ញាទីក្រុងប៉ារីស ឬជាសមាជិកនៃអង្គការ ហើយអង្គការអន្តររដ្ឋាភិបាលនេះប្រកាសថា ខ្លួនត្រូវបានអនុញ្ញាតត្រឹមត្រូវ តាមនីតិវិធីផ្ទៃក្នុងដើម្បីក្លាយជាភាគីសន្ធិសញ្ញានេះ ហើយប្រកាសថា:

(i) ខ្លួនមានសមត្ថកិច្ចផ្តល់ប្រកាសនីយបត្រតក្កកម្មដែលមានអានុភាពលើប្រទេសជាសមាជិករបស់ខ្លួន ឬ

(ii) ខ្លួនមានសមត្ថកិច្ចចំពោះបញ្ហាទាំងឡាយដែលគ្រប់គ្រងដោយសន្ធិសញ្ញានេះ និងមានច្បាប់ផ្ទាល់ខ្លួនដែលចងភ្ជាប់រដ្ឋជាសមាជិកទាំងអស់ ដែលពាក់ព័ន្ធនឹងបញ្ហាទាំងឡាយដែលគ្រប់គ្រងដោយសន្ធិសញ្ញានេះ។ អង្គការអន្តររដ្ឋាភិបាលនេះមានឬដឹកនាំការិយា ល័យមួយតាមតំបន់ដើម្បីផ្តល់ប្រកាសនីយបត្រតក្កកម្ម ដែលមានអានុភាពក្នុងដែនដីរបស់ខ្លួន តាមច្បាប់ផ្ទាល់ខ្លួននេះ។

លើកលែងតែកថាខណ្ឌទី(៣) សេចក្តីប្រកាសនេះត្រូវធ្វើឡើងនៅពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សសច្ចាប័ន ឬការចូលជាសមាជិក។

(៣) [ អង្គការប្រកាសនីយបត្រតក្កកម្មតំបន់ ]

អង្គការប្រកាសនីយបត្រតក្កកម្មអឺរ៉ុប អង្គការប្រកាសនីយបត្រតក្កកម្មអឺរ៉ុប-អាស៊ី និងអង្គការកម្មសិទ្ធិឧស្សាហកម្មតំបន់អាហ្វ្រិក ដែលបានធ្វើសេចក្តីប្រកាសតាមកថាខណ្ឌទី(២)(i)ឬ(ii) ក្នុងសន្និសីទការទូតដែលអនុម័តសន្ធិសញ្ញានេះ អាចក្លាយជាភាគីនៃសន្ធិសញ្ញានេះ ក្នុងឋានៈជាអង្គការអន្តររដ្ឋាភិបាល ប្រសិនបើនៅពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក អង្គការនេះប្រកាសថា ខ្លួនត្រូវបានអនុញ្ញាតត្រឹមត្រូវ តាមនីតិវិធីផ្ទៃក្នុង ដើម្បីក្លាយជាភាគីនៃសន្ធិសញ្ញានេះ។

(៤) [ការផ្តល់សច្ចាប័នឬការចូលជាសមាជិក]

រដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលណាមួយដែលបានបំពេញលក្ខខណ្ឌ ក្នុងកថាខណ្ឌទី(១) ទី(២)ឬទី(៣) អាចតម្កល់:

(i) លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ប្រសិនបើបានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ឬ

(ii) លិខិតុបករណ៍នៃការចូលជាសមាជិកប្រសិនបើមិនបានចុះហត្ថលេខាលើសន្ធិសញ្ញានេះ។

## មាត្រា២១

## ការចូលជាធរមាន កាលបរិច្ឆេទអានុភាព នៃការផ្តល់សច្ចាប័ននិងការចូលជាសមាជិក

(១) [ការចូលជាធរមាននៃសន្ធិសញ្ញានេះ]

សន្ធិសញ្ញានេះត្រូវចូលជាធរមាន៣(បី)ខែបន្ទាប់ពីមានលិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកនៃរដ្ឋចំនួន១០(ដប់) ត្រូវបានតម្កល់ជូនអគ្គនាយក។

(២) [កាលបរិច្ឆេទអានុភាពនៃការផ្តល់សច្ចាប័ននិងការចូលជាសមាជិក]

សន្ធិសញ្ញានេះត្រូវមានអានុភាពលើ:

(i) រដ្ឋ១០(ដប់)ដូចមានចែងក្នុងកថាខណ្ឌទី(១)ចាប់ពីកាលបរិច្ឆេទដែលសន្ធិសញ្ញានេះចូលជាធរមាន

(ii) រដ្ឋផ្សេងទៀត ចាប់ពីពេលផុតកំណត់៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកជូនអគ្គនាយក ឬពីកាលបរិច្ឆេទបន្ទាប់ណាមួយដែលបានបញ្ជាក់ក្នុងលិខិតុបករណ៍នេះ ប៉ុន្តែមិនត្រូវឱ្យលើស៦(ប្រាំមួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់នេះ។

(iii) អង្គការប្រកាសនីយបត្រតក្កកម្មអឺរ៉ុប អង្គការប្រកាសនីយបត្រតក្កកម្មអឺរ៉ុប-អាស៊ី និងអង្គការកម្មសិទ្ធិឧស្សាហកម្មតំបន់អាហ្វ្រិកចាប់ពីពេលផុតកំណត់៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ឬពីកាលបរិច្ឆេទបន្ទាប់ណាមួយដែលបានបង្ហាញក្នុងលិខិតុបករណ៍នេះ ប៉ុន្តែមិនត្រូវឱ្យលើស៦(ប្រាំមួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់នេះ ប្រសិនបើលិខិតុបករណ៍នេះត្រូវបានតម្កល់បន្ទាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានេះ តាមកថាខណ្ឌទី(១) ឬ ក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីការចូលជាធរមាននៃសន្ធិសញ្ញានេះ ប្រសិនបើ

លិខិតុបករណ៍នេះត្រូវបានតម្កល់មុនការចូលជាធរមាននៃសន្ធិសញ្ញានេះ

(iv) អង្គការអន្តររដ្ឋាភិបាលណាមួយផ្សេងទៀត ដែលអាចក្លាយជាភាគីនៃសន្ធិសញ្ញានេះ ចាប់ពីពេលផុតកំណត់៣(បី)ខែ បន្ទាប់ពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ឬពីកាលបរិច្ឆេទបន្ទាប់ណាមួយដែលបានបង្ហាញក្នុងលិខិតុបករណ៍នេះ ប៉ុន្តែមិនត្រូវឱ្យលើស៦(ប្រាំមួយ)ខែបន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់នេះ។

## មាត្រា២២

## ការអនុវត្តន៍សន្ធិសញ្ញាចំពោះសំណុំលិខិតស្នើសុំនិងប្រកាសនីយបត្រតក្កកម្មដែលមានស្រាប់

(១) [ គោលការណ៍ ]

លើកលែងតែកថាខណ្ឌទី(២) ភាគីហត្ថលេខីត្រូវយកបទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ និងបទបញ្ជា ក្រៅពីមាត្រា៥និងមាត្រា៦(១)និង(២)និងបទបញ្ជាពាក់ព័ន្ធ ទៅអនុវត្តចំពោះសំណុំលិខិតស្នើសុំទាំងឡាយដែលកំពុងព្យួរទុក និងចំពោះប្រកាសនីយបត្រតក្កកម្មដែលកំពុងមានអានុភាពតាមកាលបរិច្ឆេទដែលសន្ធិសញ្ញានេះចងភ្ជាប់ភាគីហត្ថលេខីនេះ តាមមាត្រា២១ ។

(២) [ នីតិវិធី ]

ភាគីហត្ថលេខី មិនតម្រូវឱ្យអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះនិងបទបញ្ជាចំពោះដំណាក់កាលណាមួយនៃនីតិវិធីពាក់ព័ន្ធសំណុំលិខិតស្នើសុំ និងប្រកាសនីយបត្រតក្កកម្មដូចមានចែងក្នុងកថាខណ្ឌទី(១) ប្រសិនបើនីតិវិធីនេះបានចាប់ផ្តើមមុនកាលបរិច្ឆេទដែលសន្ធិសញ្ញានេះចងភ្ជាប់ភាគីហត្ថលេខី តាមមាត្រា២១។

## មាត្រា២៣

## ខដាក់លក្ខខណ្ឌ

(១) [ ខដាក់លក្ខខណ្ឌ ]

រដ្ឋឬអង្គការអន្តររដ្ឋាភិបាលណាមួយអាចប្រកាសតាមរយៈខដាក់លក្ខខណ្ឌថាបទប្បញ្ញត្តិនៃមាត្រា៦(១) មិនត្រូវអនុវត្តចំពោះលក្ខខណ្ឌ ណាមួយទាក់ទងនឹងការរួមបញ្ចូលតែមួយនៃតក្កកម្ម ដែលអាចអនុវត្តក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ចំពោះសំណុំលិខិតស្នើសុំអន្តរជាតិ។

(២) [ បែបបទ ]

ខដាក់លក្ខខណ្ឌណាមួយក្នុងកថាខណ្ឌទី(១) ត្រូវធ្វើឡើងក្នុងសេចក្តីប្រកាស អមជាមួយលិខិតុ-បករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកសន្ធិសញ្ញានេះ ដោយរដ្ឋឬអង្គការអន្តររដ្ឋាភិបាលដែលធ្វើខដាក់លក្ខខណ្ឌ។

(៣) [ ការដកចេញ ]

ខដាក់លក្ខខណ្ឌណាមួយក្នុងកថាខណ្ឌទី(១) អាចដកចេញពេលណាក៏បាន។

(៤) [ ការហាមឃាត់ខដាក់លក្ខខណ្ឌផ្សេងទៀត ]

ខដាក់លក្ខខណ្ឌចំពោះសន្ធិសញ្ញានេះក្រៅពីខដាក់លក្ខខណ្ឌដែលធ្វើឡើងតាមកថាខណ្ឌទី(១) មិនត្រូវបានអនុញ្ញាតឡើយ។

## មាត្រា២៤

## ការប្រកាសដកខ្លួនចេញពីសន្ធិសញ្ញា

(១) [ ការជូនដំណឹង ]

ភាគីហត្ថលេខីណាមួយ អាចប្រកាសដកខ្លួនចេញពីសន្ធិសញ្ញា ដោយជូនដំណឹងទៅអគ្គនាយក។

(២) [ កាលបរិច្ឆេទអានុភាព ]

ការប្រកាសដកខ្លួនចេញណាមួយ ត្រូវមានអានុភាពមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកបានទទួលសេចក្តីជូនដំណឹង ឬ តាមកាលបរិច្ឆេទបន្ទាប់ណាមួយដែលបង្ហាញក្នុងការជូនដំណឹង។ ការប្រកាសដកខ្លួនចេញ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តន៍សន្ធិសញ្ញានេះចំពោះសំណុំលិខិតស្នើសុំដែលកំពុងព្យួរទុក ឬ ចំពោះប្រកាសនីយបត្រតតក្កកម្មណាមួយដែលកំពុងមានអានុភាពពាក់ព័ន្ធនឹងការប្រកាសដកខ្លួនចេញនៃភាគីហត្ថលេខី នៅពេលចូលជាធរមាននៃការប្រកាសដកខ្លួនចេញនេះ។

## មាត្រា២៥

## ភាសានៃសន្ធិសញ្ញា

(១) [ អត្ថបទយថាភូត ]

សន្ធិសញ្ញានេះត្រូវចុះហត្ថលេខាជាឯកសារដើមតែមួយ ជា ភាសាអង់គ្លេស ភាសាអារ៉ាប់ ភាសាចិន ភាសាបារាំង ភាសារុស្សី និងភាសាអេស្ប៉ាញ។ អត្ថបទទាំងនេះមានតម្លៃដូចគ្នា។

(២) [ អត្ថបទផ្លូវការ ]

អត្ថបទផ្លូវការជាភាសាណាមួយក្រៅពីភាសាដែលមានចែងក្នុងកថាខណ្ឌទី(១)ត្រូវបង្កើតដោយអគ្គនាយក បន្ទាប់ពីពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។ ជាគោលបំណងនៃកថាខណ្ឌនេះ ភាគីដែលពាក់ព័ន្ធមានន័យថា រដ្ឋណាមួយដែលជាភាគីសន្ធិសញ្ញានេះ ឬដែលអាចក្លាយជាភាគីសន្ធិសញ្ញានេះតាមមាត្រា២០(១) ដែលមានភាសារបស់ខ្លួនជាផ្លូវការ ឬ ប្រើភាសាផ្លូវការណាមួយក្នុងចំណោមភាសាផ្លូវការទាំងអស់ និងអង្គការប្រកាសនីយបត្រតក្កកម្មអឺរ៉ុប អង្គការប្រកាសនីយបត្រតក្កកម្មអឺរ៉ុប-អាស៊ី និងអង្គការកម្មសិទ្ធិឧស្សាហកម្មតំបន់អាហ្វ្រិក និងអង្គការអន្តររដ្ឋាភិបាលផ្សេងទៀតដែលជាភាគីនៃសន្ធិសញ្ញានេះ ឬ ដែលអាចក្លាយជាភាគីនៃសន្ធិសញ្ញានេះ ប្រសិនបើមានភាសាណាមួយជាភាសាផ្លូវការ។

(៣) [ អត្ថបទយថាភូតដែលយកជាគោល ]

ក្នុងករណីមានយោបល់ផ្សេងគ្នាលើការបកប្រែរវាងអត្ថបទយថាភូតនិងអត្ថបទផ្លូវការ អត្ថបទ

យថាភូតត្រូវចាត់ទុកជាអត្ថបទគោល។

## មាត្រា២៦

## ការចុះហត្ថលេខានៃសន្ធិសញ្ញា

សន្ធិសញ្ញានេះនៅតែបើកចំហសម្រាប់ចុះហត្ថលេខាចំពោះរដ្ឋណាមួយដែលអាចក្លាយជាភាគីនៃសន្ធិសញ្ញានេះតាមមាត្រា២០(១) និងចំពោះអង្គការប្រកាសនីយបត្រតក្កកម្មអឺរ៉ុប អង្គការប្រកាសនីយបត្រតក្កកម្មអឺរ៉ុប-អាស៊ីនិងអង្គការកម្មសិទ្ធិឧស្សាហកម្មតំបន់អាហ្វ្រិក នៅឯការិយាល័យកណ្តាលនៃអង្គការ ក្នុងរយៈពេល១(មួយ)ឆ្នាំបន្ទាប់ពីការអនុម័តសន្ធិសញ្ញានេះ។

## មាត្រា២៧

## ការតម្កល់ ការចុះបញ្ជី

(១) [ ការតម្កល់ ]

សន្ធិសញ្ញានេះត្រូវតម្កល់ជូនអគ្គនាយក។

(២) [ ការចុះបញ្ជី ]

អគ្គនាយកត្រូវចុះបញ្ជីសន្ធិសញ្ញានេះនៅឯលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ។